Disability Rights California

*California's protection & advocacy system*

# បណ្ណព័ត៌មានស្ដីពីការរើសអើងលើពិការភាព៖ សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ

*កញ្ញា 2019 ឯកសារបោះពុម្ពផ្សាយ #7143.06 - Cambodian*

## សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ

សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ គឺជាសេវាដឹកជញ្ជូនសាធារណៈមួយសម្រាប់បុគ្គលដែលមានពិការភាព ដែលមិនអាចប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈបាន។ ភ្នាក់ងារសេវាដឹកជញ្ជូនសាធារណៈ ត្រូវបានតម្រូវដោយច្បាប់ស្ដីពីពលរដ្ឋអាមេរិកាំងដែលមានពិការភាព (Americans with Disabilities Act, ADA) ឲ្យផ្ដល់ជូននូវសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះ។

ភ្នាក់ងារដឹកជញ្ជូន ត្រូវផ្ដល់ជូននូវសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការក្នុងរយៈចម្ងាយ 3/4 ម៉ាយនៃផ្លូវរត់របស់រថយន្តក្រុង ឬស្ថានីយផ្លូវដែកណាមួយ។ សេវានេះ ត្រូវមានផ្ដល់ជូនក្នុងថ្ងៃដូចគ្នា និងក្នុងម៉ោងដូចគ្នាទៅនឹងសេវាដឹកជញ្ជូនធម្មតាដែរ។ គេអាចគិតប្រាក់បន្ថែមពីអ្នកសម្រាប់សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះ ប៉ុន្តែថ្លៃធ្វើដំណើរនេះមិនអាចថ្លៃជាងមួយគុណនឹងពីរនៃថ្លៃធ្វើដំណើរធម្មតានោះទេ។

## សិទ្ធិទទួលបានសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ

អ្នកមានសិទ្ធិទទួលបានសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ ប្រសិនបើអ្នកមិនអាចប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈបានដោយសារបញ្ហាពិការភាពរបស់អ្នក។ ដើម្បីកំណត់ថាតើអ្នកអាចប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈបានដែរឬអត់នោះ ភ្នាក់ងារដឹកជញ្ជូន ត្រូវធ្វើការពិចារណាលើកត្តាមួយចំនួន។ កត្តាទាំងអស់នោះរួមមាន ពិការភាពមិនអាចដើរបាន ឬប្រើរទេះរុញទៅមកពីចំណតដឹកជញ្ជូន សមត្ថភាពនៃការចូលនិងចេញពីស្ថានីយ សមត្ថភាពក្នុងការផ្ដល់សញ្ញាដើម្បីឈប់ និងសមត្ថភាពក្នុងការគ្រប់គ្រងស្ថានការមិនបានព្រៀងទុកណាមួយ។ The Disability Rights Education & Defense Fund (មូលនិធិការពារនិងអប់រំ

សិទ្ធិជនពិការ) មានព័ត៌មានបន្ថែមអំពីបញ្ហានេះ៖
https://dredf.org/ADAtg/elig.shtml#appendix1

## ការស្នើសុំសេវាកម្ម

ទាក់ទងទៅភ្នាក់ងារដឹកជញ្ជូនក្នុងមូលដ្ឋានរបស់អ្នក ដើម្បីស្នើសុំការប្រើប្រាស់សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនៅក្នុងមូលដ្ឋានរបស់អ្នក។ ទីភ្នាក់ងារនីមួយៗ មានទំនួលខុសត្រូវក្នុងការបង្កើតដំណើរការត្រួតពិនិត្យផ្ទាល់ខ្លួន ដូចនេះលក្ខខណ្ឌតម្រូវនានាអាចមានការខុសគ្នាក្នុងពីភ្នាក់ងារដឹកជញ្ជូនមួយទៅភ្នាក់ងារដឹកជញ្ជូនមួយទៀត។ ទីភ្នាក់ងារសេវាដឹកជញ្ជូនភាគច្រើន មានគេហទំព័រមួយដែលមានទម្រង់ពាក្យស្នើសុំដែលអ្នកអាចបំពេញនិងប្រគល់ជូនតាមប្រព័ន្ធអនឡាញបាន។ អ្នកក៏អាចប្រគល់លិខិតមួយច្បាប់ទៅកាន់ភ្នាក់ងារនោះដើម្បីធ្វើការស្នើសុំសេវាបានផងដែរ។ លិខិតគំរូ ត្រូវបានបញ្ចូលនៅខាងចុងនៃប័ណ្ណព័ត៌មាននេះ។ ភ្នាក់ងារដឹកជញ្ជូន មិនត្រូវគិតប្រាក់ពីអ្នកនោះទេ សម្រាប់ការស្នើសុំសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះ។

ភ្នាក់ងារដឹកជញ្ជូន អាចស្នើសុំឲ្យអ្នកផ្តល់អំណះអំណាងគាំទ្រលើសំណើសុំសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការរបស់អ្នក ជាមួយនឹងលិខិតមួយច្បាប់ពីវេជ្ជបណ្ឌិតរបស់អ្នក។ ភ្នាក់ងារនេះ ក៏អាចស្នើសុំឲ្យអ្នកចូលរួមក្នុងការសម្ភាសដោយផ្ទាល់ ឬធ្វើការវាយតម្លៃដើម្បីកំណត់ថាតើអ្នកមានសិទ្ធិទទួលបានសេវានេះដែរឬទេ។

ភ្នាក់ងារដឹកជញ្ជូន ត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំរបស់អ្នកនៅក្នុងរយៈពេល 21 ថ្ងៃ។ ប្រសិនបើភ្នាក់ងារនោះ ពុំបានឆ្លើយតបឲ្យបានទាន់ពេលវេលាទេ ភ្នាក់ងារនោះត្រូវចាប់ផ្តើមសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះ។ គេអាចត្រូវបានបញ្ឈប់ផ្តល់សេវានានាបាន ប្រសិនបើចុងក្រោយពាក្យស្នើសុំរបស់អ្នកត្រូវបានគេបដិសេធចោល។ ភ្នាក់ងារសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ ត្រូវបញ្ជាក់ពីមូលហេតុជាក់លាក់ឲ្យអ្នកបានជ្រាប សម្រាប់ការបដិសេធពាក្យស្នើសុំរបស់អ្នកនេះ។

ប្រសិនបើពាក្យស្នើសុំរបស់អ្នកទទួលបានការយល់ព្រម នោះភ្នាក់ងារសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ គប្បីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នក ដោយរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម៖

- ឈ្មោះរបស់អ្នក
- ឈ្មោះរបស់អ្នកផ្តល់សេវាដឹកជញ្ជូន
- លេខទូរសព្ទសម្រាប់អ្នកសម្របសម្រួលសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ
- កាលបរិច្ឆេទផុតកំណត់នៃសិទ្ធិទទួលបានសេវា (ជាទូទៅមានរយៈពេលពីមួយឆ្នាំទៅបីឆ្នាំ ហើយអ្នកអាចដាក់ពាក្យសុំបន្តសេវារបស់អ្នកបានបន្ទាប់ពីរយៈពេលផុតកំណត់នោះ) និង

- លក្ខខណ្ឌ ឬដែនកំណត់ណាមួយលើសិទ្ធិទទួលបានរបស់អ្នក។ ឧទាហរណ៍ អ្នកអាចមានសិទ្ធិទទួលបានសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការសម្រាប់ផ្លូវចរាចរណ៍ណាមួយ ប៉ុន្តែមិនទទួលបានសម្រាប់ផ្លូវដទៃទៀត។

## ការកំណត់ពេលសេវាកម្ម

នៅពេលណាដែលមានការឯកភាព អ្នកអាចកំណត់ពេលវេលាធ្វើដំណើរបាន ដោយអនុវត្តតាមដំណើរការនៃការកំណត់ពេលរបស់ភ្នាក់ងារដឹកជញ្ជូនរបស់អ្នក។ ភ្នាក់ងារដឹកជញ្ជូន ត្រូវបានតម្រូវឲ្យផ្តល់សេវានៅថ្ងៃបន្ទាប់ និងត្រូវយល់ព្រមក្នុងការទៅយកអ្នកក្នុងរយៈពេលមួយម៉ោងបន្ទាប់ពីពេលដែលអ្នកបានធ្វើការស្នើសុំ។

ភ្នាក់ងារដឹកជញ្ជូនត្រូវអនុញ្ញាតឲ្យអ្នកធ្វើដំណើរជាមួយអ្នកថែទាំផ្ទាល់ខ្លួនម្នាក់។ អ្នកថែទាំផ្ទាល់ខ្លួន គឺជាបុគ្គលណាម្នាក់ដែលជួយអ្នកធ្វើកិច្ចការមួយចំនួនក្នុងអំឡុងពេលជិះរថយន្ត និងនៅកន្លែងគោលដៅ។ ភ្នាក់ងារដឹកជញ្ជូន អាចមិនគិតថ្លៃធ្វើដំណើរសម្រាប់អ្នកថែទាំផ្ទាល់ខ្លួនរបស់អ្នកនោះទេ។ ប្រសិនបើអ្នកត្រូវការអ្នកថែទាំណាម្នាក់ ឬជឿជាក់ថាពេលខ្លះអ្នកអាចត្រូវការអ្នកថែទាំម្នាក់នៅក្បែរដូចនេះ អ្នកគប្បីបញ្ជូលព័ត៌មាននោះទៅក្នុងពាក្យស្នើសុំរបស់អ្នក។

ភ្នាក់ងារដឹកជញ្ជូន ក៏ត្រូវអនុញ្ញាតឲ្យអ្នកមានអ្នកអមដំណើរជាមួយអ្នកយ៉ាងតិចម្នាក់ផងដែរ។ អ្នកអមដំណើរ គឺជាបុគ្គលណាម្នាក់ដែលនឹងត្រូវធ្វើដំណើរជាមួយអ្នកដើម្បីអមដំណើរអ្នក ឬធ្វើជាមិត្តភក្តិរបស់អ្នក។ អ្នកថែទាំអ្នក មិនត្រូវបានរាប់បញ្ចូលថាជាអ្នកអមដំណើរនោះទេ។ ភ្នាក់ងារដឹកជញ្ជូន មានសិទ្ធិក្នុងការគិតថ្លៃធ្វើដំណើរលើអ្នកអមដំណើររបស់អ្នក ប៉ុន្តែថ្លៃធ្វើដំណើរនោះ មិនអាចថ្លៃជាងគុណនឹងពីរនៃថ្លៃសេវាធ្វើដំណើរធម្មតានោះទេ។

## ការបដិសេធ និងការបាត់បង់សេវាកម្ម

អ្នកក៏អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍សម្រាប់ការបដិសេធលើសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះបានផងដែរ។ បណ្តឹងឧទ្ធរណ៍ត្រូវទទួលបានក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីការបដិសេធលើការស្នើសុំរបស់អ្នក។ ភ្នាក់ងារខ្លះ អាចផ្តល់ពេលវេលាបន្ថែមដល់អ្នកសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍នេះ។ អ្នកអាចដាក់បណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ ឬជាលាយលក្ខណ៍អក្សរក៏បាន។

ភ្នាក់ងារដឹកជញ្ជូន មានពេល 30 ថ្ងៃ ដើម្បីធ្វើការឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍របស់អ្នក។ ការឆ្លើយតបត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ប្រសិនបើភ្នាក់ងារនោះ ពុំបានឆ្លើយតបឲ្យបានទាន់ពេលវេលាទេ ភ្នាក់ងារនោះ ត្រូវផ្តល់ជូននូវសេវាកម្មតែម្តង លើកលែងតែ និងទាល់តែខ្លួនបដិសេធលើបណ្តឹងឧទ្ធរណ៍នោះ។

ភ្នាក់ងារដឹកជញ្ជូន អាចបញ្ឈប់ ឬពន្យារពេលសេវាកម្មរបស់អ្នកបាន ប្រសិនបើអ្នកពាក់ព័ន្ធនឹងអំពើហិង្សា ការបង្កការរំខានធ្ងន់ធ្ងរ ឬសកម្មភាពខុសច្បាប់ ឬប្រសិនបើអ្នកមានទម្រង់នៃការខកខានការធ្វើដំណើរដែលបានកំណត់ពេលវេលារួចជាញឹកញាប់។ គ្រោះថ្នាក់ ឬឧបទ្ទវហេតុមួយលើក មិនចាត់ទុកជាទម្រង់នៃការខកខាននេះទេ។ មានតែសកម្មភាពដោយចេតនា ដដែលៗ ឬជាប្រចាំប៉ុណ្ណោះ ដែលគប្បីត្រូវចាត់ទុកជាទម្រង់នៃការខកខានការធ្វើដំណើរនេះ។

ភ្នាក់ងារដឹកជញ្ជូន ត្រូវជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ ថាតើខ្លួនមានគម្រោងក្នុងការបញ្ឈប់ឬពន្យារពេលសេវាកម្មដែរឬទេ។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ពីសេវាជាក់លាក់ណាមួយដែលពួកគេគ្រោងនឹងធ្វើការពន្យារពេល និងត្រូវបញ្ជាក់ពីមូលហេតុនៃការពន្យារពេលនេះ។ ការជូនដំណឹងនេះ ក៏ត្រូវផ្តល់ជូននូវកាលបរិច្ឆេទដែលសេវាកម្មនោះនឹងត្រូវបន្តវិញផងដែរ។ ភ្នាក់ងារដឹកជញ្ជូន គប្បីផ្តល់ឱកាសដល់អ្នកក្នុងការដាក់បណ្តឹងឧទ្ធរណ៍លើការពន្យារពេលនោះផងដែរ។ សេវាកម្ម គប្បីត្រូវបន្តផ្តល់ជូនក្នុងអំឡុងដំណើរការនៃបណ្តឹងឧទ្ធរណ៍នេះ។

ភ្នាក់ងារដឹកជញ្ជូន អាចតម្រូវឲ្យមានការបញ្ជាក់ជាថ្មីចំពោះសិទ្ធិទទួលបានសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះ។ អ្នកអាចបាត់បង់សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ ប្រសិនបើភ្នាក់ងារកំណត់ថា អ្នកលែងមានសិទ្ធិទទួលបានសេវាកម្មនេះទៀត។

## ធនធានបន្ថែម

អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ លក្ខខណ្ឌវិនិច្ឆ័យនៃសិទ្ធិទទួលបានសេវា និងការដាក់ពាក្យសុំនៅទីនេះ៖

- គេហទំព័ររបស់ Federal Transit Administration (រដ្ឋបាលសេវាដឹកជញ្ជូនរបស់សហព័ន្ធ)៖
  - សារាចរណែនាំរបស់ FTA ស្តីពីគោលការណ៍ណែនាំរបស់ ADA សម្រាប់ភ្នាក់ងារដឹកជញ្ជូន៖ https://www.transit.dot.gov/sites/fta.dot.gov/files/docs/Final_FTA_ADA_Circular_C_4710.1.pdf
- គេហទំព័រ Disability Rights Education & Defense Fund (មូលនិធិការពារ និងអប់រំសិទ្ធិជនពិការ)៖
  - ឯកសារបោះពុម្ពផ្សាយស្តីពីសិទ្ធិទទួលបានសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការរបស់ ADA៖ https://dredf.org/news/publications/ada-paratransit-eligibility/
  - មគ្គុទេសក៍ណែនាំអំពីប្រធានបទទាក់ទងនឹងសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការរបស់ ADA៖ https://dredf.org/ADAtg/elig.shtml

## បណ្តឹងរដ្ឋបាល

ការិយាល័យសិទ្ធិពលរដ្ឋរបស់រដ្ឋបាលសេវាដឹកជញ្ជូនរបស់សហព័ន្ធ (Federal Transit Administration, FTA) មានទំនួលខុសត្រូវលើការត្រួតពិនិត្យតាមការអនុវត្តបទប្បញ្ញត្តិសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការរបស់សហព័ន្ធនេះ។ ប្រសិនបើអ្នកជឿជាក់ថា ទីភ្នាក់ងារដឹកជញ្ជូនរបស់អ្នក ពុំបានអនុវត្តតាមបទប្បញ្ញត្តិទាំងនេះ បានបដិសេធដោយពុំត្រឹមត្រូវលើសេវាកម្មរបស់អ្នក ឬមិនបានផ្តល់ឱកាសដល់អ្នកក្នុងការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ខ្លួន អ្នកអាចដាក់ពាក្យបណ្តឹងទៅកាន់ FTA បាន។ FTA នឹងធ្វើការស៊ើបអង្កេតលើពាក្យបណ្តឹងនានា និងពិនិត្យមើលក្រែងមានការបំពានច្បាប់ ADA ណាមួយដោយទីភ្នាក់ងារដឹកជញ្ជូន។ បន្ទាប់មក FTA នឹងជូនដំណឹងដល់អ្នកអំពីការរំលោភបំពានច្បាប់

ទាំងនេះ និងកំណត់នូវកាលបរិច្ឆេទផុតកំណត់សម្រាប់ទីភ្នាក់ងារនោះធ្វើការដោះស្រាយបញ្ហា។

**ពាក្យបណ្ដឹង FTA៖**

Federal Transit Administration
Office of Civil Rights
Attention: Complaint Team
East Building, 5th Floor – TCR
1200 New Jersey Avenue, SE
Washington, DC 20590

ទម្រង់បែបបទពាក្យបណ្ដឹង៖ [https://www.transit.dot.gov/regulations-and-guidance/civil-rights-ada/fta-civil-rights-complaint-form](https://www.transit.dot.gov/regulations-and-guidance/civil-rights-ada/fta-civil-rights-complaint-form)

ទូរសព្ទ៖ 1-888-446-4511

នាយកដ្ឋានលំនៅដ្ឋាននិងការងារស្មើភាពគ្នា (Department of Fair Employment and Housing, DFEH) ពង្រឹងការអនុវត្តច្បាប់ស្ដីពីសិទ្ធិពលរដ្ឋរបស់រដ្ឋ។ ការរំលោភបំពានណាមួយទៅលើច្បាប់ ADA ក៏ជាការរំលោភទៅលើច្បាប់រដ្ឋផងដែរ។  ប្រសិនបើអ្នកជឿជាក់ថា ទីភ្នាក់ងារដឹកជញ្ជូនបានរើសអើងមកលើអ្នក អ្នកក៏អាចដាក់ពាក្យបណ្ដឹងជាមួយ DFEH បានផងដែរ។ ពាក្យបណ្ដឹងទៅកាន់ DFEH ត្រូវតែធ្វើឡើងក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីមានសកម្មភាពរើសអើងនេះ។ អ្នកអាចដាក់បណ្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចរបស់ DFEH ទៅកាន់នាយក DFEH ក្នុងរយៈពេល 10 ថ្ងៃក្រោយចេញសេចក្ដីសម្រេចនោះ។ សូមមើល 2 C.C.R. ផ្នែកទី 10033.

**បណ្ដឹងទៅកាន់ DFEH៖**

ការដាក់ពាក្យបណ្ដឹងតាមប្រព័ន្ធអនឡាញ៖ **[https://www.dfeh.ca.gov/filing-a-complaint-online/](https://www.dfeh.ca.gov/filing-a-complaint-online/)**

ទូរសព្ទ៖ (800) 884-1684
TTY៖ (800) 700-2320
សំបុត្រប្រៃសណីយ៍៖ សូមទូរសព្ទទៅកាន់លេខ (800) 884-1684 និងស្នើសុំទម្រង់ពាក្យបណ្ដឹងដើម្បីព្រីនចេញនិងផ្ញើត្រឡប់មកវិញ។ សូមផ្ដល់ពេលវេលាបន្ថែមសម្រាប់ការផ្ញើតាមប្រៃយណីយ៍ និងការដំណើរការនិតិវិធី។

## បណ្ដឹងវិវាទ

ការរំលោភច្បាប់ដែលបានពិភាក្សាខាងលើ ក៏អាចពង្រឹងការអនុវត្តច្បាប់តាមរយៈពាក្យបណ្ដឹងផ្ទាល់ខ្លួនផងដែរ។ សូមមេត្តាជ្រាបថា អាជ្ញាយុកាល កំណត់ពេលវេលាសម្រាប់ការដាក់បណ្ដឹងវិវាទនេះ ហេតុនេះ អ្នកអាចបាត់បង់ឱកាសក្នុងការទាមទារ ប្រសិនបើអ្នកពុំបានចាត់វិធានការក្នុងពេលនៃអាជ្ញាយុកាលដែលមាន

ជាធរមាននេះ។ កាលបរិច្ឆេទទាំងនេះអាចមានរយៈពេលខ្លីត្រឹមពីរឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃសកម្មភាពរើសអើងត្រូវបានប្រព្រឹត្តិឡើង។ ប្រសិនបើអ្នកចង់បន្តដាក់បណ្តឹងវិវាទ អ្នកគប្បីប្រឹក្សាយោបល់ជាមួយមេធាវីណាម្នាក់ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

ប្រសិនបើអ្នកស្វែងរកសំណងខូចខាតក្នុងតម្លៃជាទឹកប្រាក់តិចជាង $10,000 នោះជម្រើសមួយទៀតគឺត្រូវដាក់ពាក្យបណ្តឹងករណីរើសអើងទៅកាន់តុលាសម្រាប់បណ្តឹងតូចតាចក្នុងមូលដ្ឋាន។ អាជ្ញាយុកាលដែលបានពិភាក្សាខាងលើនឹងត្រូវយកមកអនុវត្ត។ អ្នកមិនអាចប្រើមេធាវីបានទេក្នុងករណីអ្នកទៅប្តឹងនៅតុលាការសម្រាប់បណ្តឹងតូចតាចក្នុងមូលដ្ឋាននោះ។ នេះគឺជំណភ្ជាប់ទៅកាន់ឯកសារបោះពុម្ពផ្សាយរបស់ Disability Rights California (អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វញ៉ា) ដែលពន្យល់ពីដំណើរការនៃនីតិវិធីសម្រាប់បណ្តឹងតូចតាចពាក់ព័ន្ធនឹងករណីរើសអើង៖ **https://www.disabilityrightsca.org/publications/a-guide-to-small-claims-court-how-to-sue-if-a-business-or-landlord-discriminates**

---

យើងចង់ស្តាប់មតិយោបល់របស់លោកអ្នក! សូមបំពេញនូវការស្ទង់មតិខាងក្រោមអំពីឯកសារបោះពុម្ពផ្សាយរបស់យើង និងប្រាប់យើងថាអ្វីដែលយើងកំពុងធ្វើនេះមានលក្ខណៈដូចម្តេចដែរ! [ធ្វើការស្ទង់មតិ]

សម្រាប់ជំនួយផ្នែកច្បាប់ សូមទូរសព្ទទៅកាន់លេខ 800-776-5746 ឬសូមបំពេញនូវទម្រង់បែបបទស្នើសុំជំនួយ។ សម្រាប់គោលបំណងផ្សេងទៀត សូមហៅទូរសព្ទទៅកាន់លេខ 916-504-5800 (រដ្ឋកាលីហ្វញ៉ាភាគខាងជើង) 213-213-8000 (រដ្ឋកាលីហ្វញ៉ាភាគខាងត្បូង)។

*Disability Rights California (អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វញ៉ា) ត្រូវបានផ្តល់មូលនិធិដោយប្រភពខុសៗគ្នា សម្រាប់បញ្ជីពេញលេញនៃអ្នកផ្តល់មូលនិធិ សូមចូលទៅកាន់* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។

# គំរូលិខិតដើម្បីស្នើសុំសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ

[កាលបរិច្ឆេទ]

ជូនចំពោះ [ភ្នាក់ងារដឹកជញ្ជូន]៖

ខ្ញុំសរសេរលិខិតនេះដើម្បីស្នើសុំសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការ ដោយសារបញ្ហា [ពិការភាព]/ របស់ខ្ញុំ។ ខ្ញុំពុំអាចប្រើប្រាស់ប្រព័ន្ធផ្លូវរត់ដែលបានកំណត់រួចស្រេចនោះទេ ដោយសារ [រៀបរាប់អំពីឧបសគ្គនៃការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈ ឧ.ទា. ចំណតរថយន្តមិនអាចចេញចូលបាន]។

[គ្រូពេទ្យ / គ្រូពេទ្យផ្នែកវិកលចរិត / ចិត្តវិទូ / គ្រូពេទ្យព្យាបាលដោយចលនា / បុគ្គលិកសង្គមកិច្ច / គ្រូពេទ្យព្យាបាលសប្បទាវិជ្ជាជីវៈ / បុគ្គលដទៃផ្សេងទៀត (សូមរៀបរាប់)] របស់ខ្ញុំ បានចាត់ទុកសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះថាចាំបាច់ដោយផ្អែកលើពិការភាពរបស់ខ្ញុំ។ សូមមេត្តាពិនិត្យលិខិតដូចបានភ្ជាប់មកជាមួយពី [ឈ្មោះវេជ្ជបណ្ឌិត ឬអ្នកជំនាញ]។

ខ្ញុំចង់ប្រើសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការសម្រាប់ការធ្វើដំណើរខាងក្រោមជាប្រចាំ៖ [សរសេរបញ្ចូលនូវកាលបរិច្ឆេទ/ពេលវេលាធ្វើដំណើរ ទីតាំងទៅយក និងដាក់ចុះ]។

[ខ្ញុំនឹងត្រូវការជំនួយពីអ្នកថែទាំម្នាក់សម្រាប់ការធ្វើដំណើរ (មួយចំនួន/ទាំងអស់) ដើម្បីជួយខ្ញុំ (ក្នុងអំឡុងពេលជិះរថយន្ត/នៅកន្លែងគោលដៅរបស់ខ្ញុំ)។ (សូមរៀបរាប់ពីតម្រូវការអ្នកថែទាំ)។]

ច្បាប់របស់សហព័ន្ធនិងច្បាប់រដ្ឋតម្រូវឲ្យភ្នាក់ងារដឹកជញ្ជូនផ្តល់សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការជូនដល់បុគ្គលដែលមានពិការភាពដែលមិនអាចប្រើប្រាស់ប្រព័ន្ធផ្លូវរត់ដែលកំណត់ជាស្រេចបាន។ សូមធ្វើការឆ្លើយតបទៅនឹងសំណើសុំនេះ ក្នុងរយៈពេល 21 ថ្ងៃ ទៅតាមការតម្រូវដោយច្បាប់។ សូមមេត្តាកុំស្ទាក់ស្ទើរក្នុងការទាក់ទងមកខ្ញុំតាមរយៈ [លេខទូរសព្ទរបស់អ្នក និង / ឬ អ៊ីម៉ែល] ប្រសិនបើអ្នកមានជាសំណួរណាមួយនោះ។ សូមអរគុណ។

ដោយសេចក្តីគោរពអំពីខ្ញុំ

[ឈ្មោះរបស់អ្នក]
[អាសយដ្ឋានរបស់អ្នក]

# គំរូលិខិតគាំទ្រ

[កាលបរិច្ឆេទ]

គោរពជូន [ក្រុមហ៊ុន]៖

ខ្ញុំជា [គ្រូពេទ្យ / គ្រូពេទ្យផ្នែកវិកលចរិត / អ្នកចិត្តវិទូ / គ្រូពេទ្យព្យាបាលដោយចលនា / បុគ្គលិកសង្គមកិច្ច / គ្រូពេទ្យព្យាបាលសម្បទាវិជ្ជាជីវៈ/ ផ្សេងទៀត] សម្រាប់ [ឈ្មោះ] ហើយខ្ញុំដឹងច្បាស់ពីលក្ខខណ្ឌស្ថានភាព [របស់គាត់/នាង]។ [គាត់/នាង] មានពិការភាពដែលបណ្តាលឲ្យមានបញ្ហាមិនអាចបំពេញមុខងារមួយចំនួនបាន។ បញ្ហាទាំងនេះ រួមមាន [រៀបរាប់ពីបញ្ហាមិនអាចបំពេញមុខងារបាន ដែលតម្រូវឲ្យមានសេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការដែលបានស្នើសុំនេះ]។

[ឈ្មោះ] ពុំអាចប្រើប្រាស់ប្រព័ន្ធផ្លូវរត់ដែលបានកំណត់ជាស្រេចនោះទេ។ [រៀបរាប់ថាតើឧបសគ្គទាំងនោះរារាំងដល់ការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈយ៉ាងដូចម្តេចខ្លះ។ ប្រសិនបើត្រូវការអ្នកថែទាំណាម្នាក់ សូមរៀបរាប់អំពីតម្រូវការសម្រាប់អ្នកថែទាំនោះ]។

សូមអរគុណសម្រាប់ការផ្តល់សេវាដឹកជញ្ជូនពិសេសសម្រាប់ជនពិការនេះជូនដល់ [ឈ្មោះ]។

ដោយសេចក្តីគោរពអំពីខ្ញុំ

[ឈ្មោះនិងមុខតំណែង]